[illegible]

[illegible]

[illegible]



e.
390 2
KANI1

Konica

www.elibraryofcambodia.org

www.elibraryofcambodia.org

# ព្រះរាជពិធីបុណ្យ

## អុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក

១៨_១៩_២០ វិច្ឆិកា ឆ្នាំ ២០០២

## ឧបត្ថម្ភបោះពុម្ព

## ដោយក្រុមហ៊ុន កូនីកា

Konica

ព.ស ២៥៤៦ គ.ស ២០០២

0427 5/1

National Library of Cambodia

www.elibraryofcambodia.org

www.elibraryofcambodia.org

# អារម្ភកថា

ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ១៨-១៩ និងទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០២ មានទូក ង ទូកម៉ូង ជាច្រើនមកពីបណ្តា ខេត្ត-ក្រុង និង ក្រសួង មន្ទីរ មួយចំនួនចូលរួមប្រណាំង អបអរសាទរនៅរាជធានីភ្នំពេញ ដោយក្តីរីករាយ ដូចរៀងរាល់ឆ្នាំ ។

គណៈកម្មការរៀបចំព្រះរាជពិធីបុណ្យអុំទូក ដោយបានទទួលការឧបត្ថម្ភ ដោយសម្ភារៈ និងថវិកា ពីក្រុមហ៊ុន **គុនីតា** ក៏បានចាត់ការបោះពុម្ពសៀវភៅ ស្តីពីប្រវត្តិបុណ្យអុំទូកនាទសវត្សឆ្នាំ ៥០-៦០ និងក្រោយថ្ងៃជ័យជំនះ ៧ មករា ឆ្នាំ ១៩៧៩ ព្រមទាំងចំនួនទូកង ទូកម៉ូង ដែលបានចូលរួមប្រណាំង ។

សៀវភៅនេះ នឹងបានជាឯកសារដ៏សំខាន់មួយ ងាយស្រួលដល់ការស្រាវជ្រាវអំពីប្រវត្តិអុំទូក អំពីរបៀបចាត់តាំងប្រណាំងទូក អំពីឈ្មោះ ទីតាំងស្ថិតនៅរបស់ទូក នីមួយៗ អំពីចំណង់ចំណូលចិត្តរបស់ប្រជាពលរដ្ឋខ្មែរ ដែលតែងតែស្រលាញ់ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អរបស់ជាតិខ្លួន ដែលជាប់ទាក់ទងទៅនឹងការរក្សា អត្ថិភាពបូរណភាព ទឹកដីផង និងជំនឿសាសនាផង ។

សូមឧទ្ទិសឱ្យវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អរបស់ជាតិ ស្ថិតនៅជាប់ ជានិច្ចក្នុងចិត្តកូនចៅកុលបុត្រ កុលធីតាខ្មែរគ្រប់រូប ដើម្បីរួមគ្នាថែរក្សាឱ្យបានគង់វង្សនូវអត្តសញ្ញាណជាតិដ៏មានតម្លៃពុំអាចកាត់ថ្លៃបាន ។

ភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០២

គណៈកម្មការរៀបចំបុណ្យអុំទូក

www.elibraryofcambodia.org

www.elibraryofcambodia.org

# ថ្វាយព្រះពរ

ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ដ៏មហោឡារិក នាថ្ងៃទី ១៨-១៩-២០ ខែ វិច្ឆិកា ឆ្នាំ ២០០២ នេះ ទូលព្រះបង្គំជាខ្ញុំ នាយក នាយករង បុគ្គលិក កម្មករ នៃក្រុមហ៊ុន**ភូនីភា** សូមសំដែងមនោសញ្ចេតនា អបអរសាទរសប្បាយរីករាយ និង សូមលំអោនកាយ វាចាចិត្ត គោរពថ្វាយ ព្រះពរសព្ទសាធុការ បវរមហាប្រសើរ ថ្វាយព្រះករុណាជាអង្គម្ចាស់ជីវិតដ៏កល់លើត្បូង ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះរាជអគ្គមហេសីនរោត្តមមុនិនាថសីហនុ ជាទីសក្ការៈ សូមទ្រង់បានប្រកបដោយព្រះជន្មាយុ យឺនយូរ ព្រះសុខមាលភាពល្អបរិបូរណ៍ ព្រះកាយពល មាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរម សិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់ ត្បៀមក្សាន្ត ជាទីជ្រកកោនរបស់ប្រជារាស្ត្រ ជាកូន ចៅ ចៅទួត របស់ ព្រះអង្គ ជាយូរអង្វែង តរៀងទៅ ។

សូមគុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុសក្តិសិទ្ធក្នុងលោក ទេវតារក្សា ព្រះរាជាណាចក្រកម្ពុជា ទេវតារក្សាព្រះមហាស្វេតច្ឆត្រ បារមីព្រះអតីតមហាក្សត ព្រះមហាក្សត្រីយានី គ្រប់ព្រះអង្គ សូមតាមជួយអភិបាល រក្សាព្រះករុណាថ្លៃវិសេស និង សម្តេចព្រះរាជគ្គមហេសី ជាទីសក្ការៈ ជានិច្ចនិរន្តរ៍ ។

ក្រុមហ៊ុន **ភូនីភា**

( JEL Distribution (Cambodia) Pte.,Ltd. ANCO/JEL Co.Ltd )

www.elibraryofcambodia.org

# ថ្វាយព្រះពរ-ជូនពរ

ទូលព្រះបង្គំយើងខ្ញុំ ជានាយក នាយករង បុគ្គលិក កម្មករ នៃក្រុមហ៊ុន **ភូនីកា** សូមចូលរួមអបអរសាទរ ដោយមនោសញ្ចេតនា សប្បាយរីករាយយ៉ាងក្រៃលែង នាឱកាសប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ដែលប្រព្រឹត្តនៅថ្ងៃទី ១៨-១៩-២០ ខែ វិច្ឆិកា ឆ្នាំ ២០០២ នេះ ។

ក្នុងឱកាសដ៏មហាឧឡារិកនេះ ទូលព្រះបង្គំ យើងខ្ញុំសូមលំអោនកាយ វាចា ចិត្តគោរពថ្វាយព្រះពរ ជូនពរ សម្តេច ជា **ស៊ីម** ប្រធានព្រឹទ្ធសភា និង លោកជំទាវ, សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា និង ព្រះអង្គម្ចាស់ក្សត្រី, សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និង លោកជំទាវ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល អស់លោក លោកស្រី មន្ត្រីរាជការ គ្រប់មុខតំណែង ប្រជាពលរដ្ឋ និង កីឡាករ កីឡាការិនី អុំទូកទាំងអស់ សូមបានប្រកបដោយពរទាំង ៥ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ ជានិច្ចនិរន្តរ៍ ។

**ក្រុមហ៊ុន ភូនីកា**

( JEL Distribution (Cambodia) Pte.,Ltd. ANCO/JEL Co.Ltd )

www.elibraryofcambodia.org

# ប្រវត្តិបុណ្យអុំទូក បណ្តែតប្រទីប
# សំពះព្រះខែ អកអំបុក

ប្រភពពិធីបុណ្យប្រណាំងទូក

ប្រវត្តិនៃបុណ្យអុំទូក មានតាំងពីបូរមបូរាណដ៏យូរលង់មកហើយ ដែលមានចែងក្នុងពង្សាវតារ ឯកសារប្រវត្តិវិទូបរទេស ក៏ដូចជាតាមសិលាចារឹកនៃប្រាសាទអង្គរ ។ សូមបញ្ជាក់ថា បុណ្យអុំទូកនេះមានការរកស្រាយប្លែកៗគ្នាជាច្រើន ហើយវិធីធ្វើក៏មានប្លែកៗពីគ្នាខ្លះដែរ ។

ក-តាមសៀវភៅជ័យវរ្ម័នទី ៧ មាននៅក្នុងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត យើងពិដើមមានចែងថា :

នៅសម័យអង្គរ នាគ្រឹស្តសករាជសតវត្សទី ១២ ក្រុងកម្ពុជា មានសេចក្តីសុខក្សេមក្សាន្តរុងរឿងពេកស ដោយព្រះបាទជ័យវរ្ម័នទី ៧ ស្តេចចេញធ្វើសង្គ្រាមជើងទឹកបង្ក្រាបពួកចាមដោយកងទ័ពទូក ជាចំបាំងរំដោះក្រុងកម្ពុជា អោយរួចផុតស្រលះចេញពីខ្មាំងសត្រូវ "គ.ស១១៧៧-១១៨១" រឿងចំបាំងគ្រានោះ មានឆ្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន និង បន្ទាយឆ្មារ ។

ក្នុងចំណោមនោះ ឃើញមានកងទ័ពទូកយ៉ាងច្រើនមហិមា ដែល[illegible]ឆាយាត្រាផ្ទាល់នៃព្រះបាទជ័យវរ្ម័នទី ៧ ប្រថាប់ពេលលើទីព្រះទីនាំងនាវាចំបាំង ដោយទ្រង់ផ្ទួ និង ជិតអាហ៊ានស្វាហាប់ក្នុងចំណោមកងទ័ពទូកទាំងឡាយ ។

ខ- ឯកសារស្បែងប្រណាំងទូក របស់ក្រុមជំនុំទំនៀមទំលាប់លេខ ១៩.004 រៀបរៀងដោយលោក ខាច់ ម៉ែន ហៅប៉ុង អាចារ្យនៅពុទ្ធសាសនបណ្ឌិតរង ខេត្តឃ្លាំង

www.elibraryofcambodia.org

កម្ពុជាក្រោម មានចែងថា :

"សម័យលង្វែក ព.ស ២០៧១ គ.ស ១៥២៨" ព្រះបាទអង្គចន្ទ ទី ១ ទ្រង់តាំងពញាតាត ងារជាស៊ិទ្ធភូបាល ជាស្តេចត្រាញ់នៅកម្ពុជាក្រោមស្រុកបាសាក់ ។ ស្តេច ត្រាញ់នេះបានចាត់របៀបរៀបចំ ការពារស្រុកមានដូចតទៅនេះ :

ទាហានជើងទឹកចែកជា ៣ក្រុម ;

ក្រុមទី១ ហៅទ័ពស្រួច ហាត់ច្បាំងនឹងទូកដែលមានទ្រង់ទ្រាយដូចទូកប្រណាំងយើងសព្វថ្ងៃ ។

ក្រុមទី២ ហៅទ័ពជំនួយ ហាត់ច្បាំងនឹងទូកចែវពីរជួរដែលមានទ្រង់ទ្រាយដូចទូកប្រណាំងយើងសព្វថ្ងៃ ។

ក្រុមទី៣ ហៅទ័ពបាសាក់ គឺទូកធំមានដំបូល មានចែវ មានក្តោងមានទ្រង់ទ្រាយដូចជាទូកបាសាក់ ហៅទូកប៉ុកចាយ តែរាងស្តួចវែងមានដំបូលតែមួយកាត់ខាងមុខឥតជញ្ជាំង ។ល ។ជាទូកដាក់ស្បៀងអាហារសំរាប់កងទ័ព ។

របៀបបង្ហាត់ច្បាំង " តាមទំនៀមស្តេចត្រាញ់កម្ពុជាក្រោម " ស្រេចលើមន្ត្រីបួនទិស "ចតុស្តម្ភ " ដែលអនាំក្នុងឪវាទស៊ិទ្ធភូបាល ស្តេចត្រាញ់គ្រប់ជំពូកដែលបញ្ញត្តិច្បាប់សំរាប់ស្រុក ។ល ។ កំណត់ថ្ងៃពេញបូណ៌មី ខែកត្តិក រដូវអកអំបុកនោះមន្ត្រីទាំងបួនទិសត្រូវកេណ្ឌទាហានទាំងជើងទឹកជើងគោក "សមយុទ្ធ" ១ ថ្ងៃ ១ យប់រាល់ឆ្នាំ ។

ចំណែកទាហានជើងទឹកអោយទៅប្រឡងឫទ្ធិឯទន្លេពាមកន្ទោ ក្នុងខេត្តឃ្លាំងត្បិតទីនោះជាទីប្រជុំទឹក គ្រប់ខេត្តទៅមកបានស្រួល ។

តាមសៀវភៅ និងឯកសារ ជាប្រភពទាំងពីរខាងលើនេះ អាចសន្និដ្ឋានបានថាប្រទេសកម្ពុជាសម័យបុរាណ ជាប្រទេសមានកងទ័ពជើងទឹកយ៉ាងខ្លាំងពូកែ និងមានវិធីហ្វឹកហ្វឺន ពិធីសមយុទ្ធកងទ័ពនេះ ជាប្រពៃណីជាប់រៀងរាល់ឆ្នាំ ហើយអាចសន្និដ្ឋាន

www.elibraryofcambodia.org

ទៀតថា ប្រទេសកម្ពុជាធ្វើពិធីនេះរៀងរហូតមក គឺចាប់តំណមកពីសម័យនគរភ្នំ ក្នុងសម័យបុរាណនេះឯង ។

គ-ឯកសារខ្លះ និយាយថា ពិធីបុណ្យអុំទូក គឺជាបុណ្យប្រពៃណីជាតិដ៏ធំមួយនៅប្រទេសកម្ពុជា ។ បុណ្យនេះមានរូបភាពប្រហាក់ប្រហែល នឹងបុណ្យប្រចាំរដូវរបស់ជនជាតិអឺរ៉ុប ដែលមានឈ្មោះថា សាំង ហ្សង់ ដែលបច្ចុប្បន្នប្រារព្ធធ្វើនៅអឺរ៉ុបខាងជើង ។

ប្រពៃណីខ្លះ មានប្រវត្តិជាប់ទាក់ទងយ៉ាងជិតស្និតទៅនឹងប្រវត្តិ នៃព្រះពុទ្ធជាម្ចាស់ ។ ប៉ុន្តែ ការបកស្រាយមួយដែលអាចយកជាការគ្រប់គ្រាន់គឺក្នុងបំណង "ដឹងគុណដល់ព្រះគង្គា និងព្រះធរណី ដែលបានផ្តល់ជីវភាពរស់នៅ និងសុខមាលភាព ចំពោះទឹកដីវិញ ដែលយើងនាំគ្នាធ្វើឱ្យកកករល្អក់" ។

ការបកស្រាយចុងក្រោយនេះ គឺដូចគ្នាបេះបិទទៅនឹងទំនៀមទំលាប់នៃព្រហ្មញ្ញសាសនា ហើយស្របទៅនឹងស្ថានភាពភូមិសាស្ត្រ ជាក់ស្តែង និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាកសិករយើង ។

ពិធីបុណ្យអុំទូក ប្រព្រឹត្តទៅនាថ្ងៃពេញបូរមី ខែកត្តិក ស្របទៅនឹងរដូវទឹកជំនន់ ដែលក្នុងរយៈពេលប៉ុន្មានខែមកហើយ បានធ្វើឱ្យបឹងបួរទាំងឡាយក្លាយទៅជាសមុទ្រដ៏ធំល្វឹងល្វើយ ហើយក៏បញ្ជាក់ទៀតថាពេលនេះស្រូវក្នុងស្រែកំពុងតែទុំហើយ ។

នៅពេលដែលទឹកទន្លេមេគង្គឈប់ជន់ " សិហា វិច្ឆកា " ទឹកជំនន់ដ៏សន្ធឹកសន្ធាប់ បានហូរចាក់ស្រោចស្រពបឹងបួរ តាមរយៈទន្លេសាប ដែលហូរពីត្បូងទៅជើង ។ ដល់រដូវទឹកស្រកដែលចាប់ផ្តើមនៅខែវិច្ឆកា ទឹកបឹងបួរហូរត្រឡប់តាមទន្លេសាបដដែល ពីជើង មកត្បូងវិញ ។

www.elibraryofcambodia.org

ទឹកជំនន់នៃទន្លេមេគង្គ ពិសេសជំនន់នៅតាមបឹងបួរ មានប្រភពមកពីប្រទេសទីបេដ៏សែនឆ្ងាយ បានផ្តល់ជីវភាពនូវស្រែចំការនៅប្រទេសកម្ពុជា ។ ដីល្បាប់ដែលបានដោយសារទឹកជំនន់នៃទន្លេបឹងបួរទាំងឡាយ បានធ្វើឲ្យដីមានជីវជាតិបង្កបាននូវធនធាន សំបូរបែបនៅក្នុងប្រទេសកម្ពុជា ។

ដំណាំទាំងឡាយ ដែលកសិករខ្មែរធ្វើតាមចង្វាក់នៃទឹកសំរក បានផ្តល់នូវផល យ៉ាងច្រើនរាំងស្កាត់គ្រោះទុរ្ភិក្ស និងផ្តល់សុភមង្គល ។ ដូច្នេះហើយបានជាដល់រដូវទឹកស្រក បុរាណខ្មែរយើងក៏កំណត់យកថ្ងៃពេញបូណ៌មី ខែកត្តិក រៀងរាល់ឆ្នាំ រៀបចំពិធី អុំទូក បណ្តែត ប្រទីប សំពះព្រះខែ អកអំបុក ដើម្បីសំដែងមនោសញ្ចេតនា ដឹងគុណចំពោះទន្លេមេគង្គ និងទន្លេសាប ដែលបានផ្តល់ជីវជាតិយ៉ាងសំខាន់បំរើវិស័យកសិកម្ម ។

ពិធីបុណ្យនេះ គេតែងប្រារព្ធធ្វើអស់ថេរវេលា ៣ថ្ងៃ គឺ ថ្ងៃ ១៤ កើត ១៥កើត និង ថ្ងៃ ១ រោច ខែកត្តិក ធ្វើនៅតាមដងទន្លេសាប នាកំពង់ផែមុខវាំង ។

ប្រភពពិធីបណ្តែតប្រទីប

ក- គម្ពីរទាថាវង្ស ភាសាបាលី មានចែងថាព្រះចង្កូមកែវទាំងបួន នៃព្រះសម្មាសម្ពុទ្ធប្រតិស្ឋាននៅទីតាំង ៤ គឺ :

ទី ១ - នៅត្រៃត្រឹង្សសួគ៌.

ទី ២ - នៅពិភពនាគ.

ទី ៣ - នៅស្រុកគន្ធារ .

ទី ៤ - នៅទន្តបុរៈកលិង្គរដ្ឋ ។

ខ- ភាណវារៈបាលី ត្រង់ពុទ្ធនមក្ការគាថា មានចែងថាស្នាមព្រះបាទ ព្រះសម្មា សម្ពុទ្ធប្រតិស្ឋាននៅទិសទាំង ៥ គឺ :

ទី ១ - នៅសុវណ្ណមាលិកបរពត

www.elibraryofcambodia.org

ទី២ - នៅសុវណ្ណបរពត

ទី៣ - នៅសុមនកូដបរពត

ទី៤ - នៅយោនកបុរី

ទី៥ - នៅស្ទឹងនម្មទា

ក- ពាក្យសរសើរព្រះបាទ " **យស្សានេ** " ទាំងបាលីទាំងសាស្ត្រាសរសើរដែរ ថាត្រូវជាស្នាម នៃព្រះសម្មាសម្ពុទ្ធ ប្រតិស្ឋាននៅទីទាំង ៥ ដូចក្នុងភាណវារៈដែរ ។

ដោយហេតុមានគម្ពីរដីកាជាប្រភពយ៉ាងនេះ បានជាពុទ្ធបរិស័ទខ្មែរយើងតែងតែធ្វើពិធី បណ្តែតប្រទីប នៅយប់ពេញបរមី ខែអស្សុជ ដែលក្រោយថ្ងៃចេញព្រះវស្សាហើយបណ្តែតប្រទីប នៅយប់ ១៤-១៥ កើត និង ១ រោច ខែកត្តិក បូជាចំពោះព្រះចូឡាមណីចេតិយ និងព្រះ ព្រះពុទ្ធបាទទៅស្ទឹងនម្មទា និង នៅទីឯទៀតដូចពោលខាងលើ ហើយជឿថា ជាការកុសលយ៉ាង ធំបានផលយ៉ាងធំបានផលយ៉ាងប្រសើរ ដើម្បីសុខចំរើនរុងរឿងដល់ខ្លួនដល់ប្រជាជន និងដល់ ប្រទេសជាតិ ។

## 1.3. ប្រវត្តនៃពិធីសំពះព្រះខែ、 អកអំបុក

តាមគម្ពីរបរមត្ថទីបនី អដ្ឋកថាចរិយាបិដក ភាសាបាលីមានចែងថា ក្នុងដើមភទ្ទកប្បនេះ ព្រះបរមពោធិសត្វនៃយើងទ្រង់យោនយកកំណើតជា សសបណ្ឌិត " កំណើតជាទន្សាយ " ។ នៅថ្ងៃពេញបូណ៌មីមួយ សសបណ្ឌិត បានអធិដ្ឋានឧបោសថសីលហើយឧទ្ទិសម៌ស:ជាទានបរមត្ថ បារមី ដើម្បីបំពេញពោធិសម្ភារអោយបានត្រាសជាព្រះពុទ្ធ ។ ព្រះឥន្ទទ្រង់ជ្រាបហេតុការណ៍ នោះក៏ទ្រង់ក្រឡាខ្លួន ជាព្រាហ្មណ៍ចាស់នោះបង្កាត់ភ្លើងភ្នក់ហើយក្នុងពេលដែលភ្លើងកំពង់ ឆេះ សន្ធោសន្ធៅ សសបណ្ឌិតពោធិសាត់ក៏រលាស់ខ្លួន ៣ ដង ដើម្បីអោយសត្វល្អិតដែលជាប់នៅនឹង រោមជ្រុះចេញរួច ក៏លោតចូលទៅក្នុងភ្នក់ភ្លើងភ្លាម ។

www.elibraryofcambodia.org

អស្ចារ្យ ភ្លើងនោះ ពុំបានឆេះសេសបញ្ជិតសោះ ឥន្ទព្រាហ្មណ៍ក៏ស្ទុះទៅពរព្រះពោធិសត្វឡើងទៅ ដល់មណ្ឌលព្រះចន្ទ ហើយទ្រង់យកថ្មាងសិលាគូររូបទន្សាយហើយឥន្ទព្រាហ្មណ៍អធិដ្ឋានថា សូមអោយរូប ទន្សាយពោធិសត្វ ដែលខ្ញុំគូរនេះនៅជាប់រហូតដល់ទីបំផុតកប្ប ។

ដោយអនុភាពទានបរមត្ថបារមីនៃព្រះពោធិសត្វផងនិងសេចក្ដីអធិដ្ឋានរបស់ ព្រះឥន្ទផង រូបទន្សាយក៏ឃើញប្រាកដក្នុងមណ្ឌលព្រះច័ន្ទដរាបដល់សព្វថ្ងៃ ។

ដោយជឿតាមរឿងនេះហើយ បាន[illegible]ពេញបូណ៌មី ខែកត្តិក រៀងរាល់ឆ្នាំខ្មែរយើងយកនំចំណី មានអំបុក និងចេកជាដើម មកបូជាព្រះច័ន្ទ ហៅថាពិធី **សំពះព្រះខែអកអំបុក** ។

www.elibraryofcambodia.org

# ព្រះរាជពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក

ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ត្រូវបានកំណត់នៅក្នុងព្រះរាជពិធីទ្វាទសមាសប្រចាំឆ្នាំ គឺជាព្រះរាជពិធីនៅក្នុងខែ កត្តិក ។ ព្រះរាជពិធីនេះ ពុំមានកំណត់ឬប្រកាន់ឈ្មោះថ្ងៃណាមួយតាមសុរិយគតិទេ គឺកំណត់យកថ្ងៃ ១៤-១៥ កើត និងថ្ងៃ ១ រោច ខែ កត្តិក ជាទៀងទាត់ រៀងរាល់ឆ្នាំ តាមប្រតិទិនច័ន្ទគតិ ។

ព្រះរាជពិធីនេះ តែងប្រារព្ធធ្វើនៅក្នុងទន្លេចតុមុខ និងនៅព្រះរាជតំណាក់ផែមុខព្រះបរមរាជវាំង ក្នុងថេរវេលា ៣ ថ្ងៃ ។

ការប្រណាំងទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក គឺជាពិធីបុណ្យដ៏ល្អប្រពៃរបស់ប្រជាជាតិយើង ដែលបង្ហាញពីទឹកចិត្តជាបុណ្យកុសល ស្រលាញ់ភាពសុខក្សេមក្សាន្ត សប្បាយរីករាយសាមគ្គីភាពទូលំទូលាយនិងជាការឆ្លុះបញ្ចាំង បង្ហាញពីមនសិការជាតិ ថាមពលក្លៀវក្លាភាពអង់អាចអំណត់ព្យាយាម និងឆន្ទះប្រយុទ្ធស្រួចស្រាល់របស់ប្រជាជនយើង ក្នុងការការពារឯករាជ្យជាតិ ការពារបូរណភាពទឹកដី ការពារអាយុជីវិតប្រជាជន ទ្រព្យសម្បត្តិ កេរដំណែល និងកិត្តិយសរបស់ជាតិ ប្រឆាំងគ្រប់ឧបាយកលឈ្លានពានរបស់ខ្មាំងសត្រូវ ។ ម្យ៉ាងទៀត ពិធីនេះ ក៏ជាការបង្ហាញពីការរីកចំរើនសំបូរបែបនៃផលិតផលកសិកម្ម ដែលជាអំណោយផលពីទឹកដីដ៏មានជីវជាតិនៃព្រោយសុវណ្ណភូមិ គួបផ្សំនឹងចរិតឧស្សាហ៍ អត់ធ្មត់ តំនិតច្នៃប្រឌិត មិនគិតពីការនឿយហត់ក្នុងការបង្កបង្កើតផលរបស់ប្រជាកសិករយើងផងដែរ ។

នៅក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាស ដែលរៀបរៀងដោយ ឧកញ៉ា ទេពពិទូរ ក្រសេម បណ្ឌិតទី១ នៅពុទ្ធសាសនបណ្ឌិត បានលើកយកកំណត់ព្រះរាជពិធី ស្តីពីរបៀបរៀបចំព្រះរាជពិធីប្រណាំងបុណ្យទូក នៅក្នុងរជ្ជកាល ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សុរាម្រិត ព.ស ២៥០១ គ.ស ១៩៥៨ នៅមុខព្រះបរមរាជវាំង ។

www.elibraryofcambodia.org

ដែលមានសេចក្ដីពណ៌នាយ៉ាងពិស្ដារ ដែលយើងសូមដកស្រង់នៃការរៀបចំពិធីនេះ ដូចតទៅ ។

## ១ ।   * ពិធីប្រណាំងទូក ឆ្នាំ ១៩៥៨ :

### * *ថ្ងៃទីមួយ គឺថ្ងៃ ១៤ កើត ខែ កត្តិក ជាថ្ងៃចាប់ផ្ដើម*

នៅវេលាម៉ោង ១៦.០០ រសៀល ពិធីប្រណាំងទូកង ទូកមូង ចាប់ដំណើរការតាមកម្មវិធីកំណត់។ ទូកដែលចូលរួមប្រណាំងពេលនោះមានប្រហែល ៣០ គូប៉ុណ្ណោះមកពីវត្តក្នុងខេត្តផ្សេងៗ ដែលនៅជិតមាត់ទន្លេ មានខេត្តកណ្ដាល ខេត្តកំពង់ចាម ជាដើម ។

ក្រោយដែលទូកមកជួបជុំគ្នាហើយ គេចាប់ផ្ដើមផ្គុំគ្នាជាគូៗ និងចេញប្រណាំងតៗគ្នាជាលំដាប់លំដោយ បណ្ដោយទឹកតាមដងដៃទន្លេសាប ។ ដើមទីចេញដំណើរទន្ទឹមនឹង វត្តភ្នំដូនពេញ ចុងទីផ្ដាច់ព្រ័ត្រ នៅចំមុខព្រះរាជតំណាក់ផែ ។ការផ្ទួរប្រណាំងទូក២គូរ ឬ ៣គូ រ ម្ដង ក៏មាន ច្រើនជាងនោះក៏មាន ។ ប្រណាំងមកដល់ចុងទីក៏សារត្រឡប់ទៅផ្ទួម្ដងទៀត សារចុះសារឡើង បីលើកក្នុងមួយថ្ងៃ គ្រប់ទាំងបីថ្ងៃ ។

ក្នុងឱកាសប្រណាំងទូក ភ្លេងតន្ត្រីព្រះរាជទ្រព្យ ភ្លេងពិណពាទ្យប្រគុំកំដរនៅព្រះរាជដំណាក់ផែ តាមរយៈទូកចុះឡើង ពិរោះរណ្ដំ គួរជក់ចិត្ត ជក់អារម្មណ៍ ។

ព្រះរាជវង្សានុវង្ស តំណាងរាស្ត្រ ក្រុមប្រឹក្សាព្រះរាជាណាចក្រ នាម៉ឺនសព្វមុខមន្ត្រីទាំងទាហាន ទាំងស៊ីវិល មន្ត្រីកិត្តិយស ជួបជុំនៅព្រះទីនាំងមករ ព្រះទីនាំងបល្ល័ង្កតាំងពីម៉ោង ១៤.០០ រសៀល ដើម្បីរង់ចាំក្រាបបង្គំគាល់ព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះមហាក្សត្រិយានី ដែលនឹងស្ដេចយាងមកប្រថាប់ក្នុងព្រះរាជតំណាក់ផែ នៅវេលាម៉ោង ១៦.០០ រសៀល ។

www.elibraryofcambodia.org

ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរភូមិន្ទ ចាំគោរពអមសងខាងផ្លូវ តាំងពី មុខទ្វារជ័យនៃព្រះបរមរាជវាំង រហូតដល់មាត់ច្រាំង ទាហានសេះក្រុមរក្សាព្រះអង្គចាំគោរពអមតាមមាត់ជណ្ដើរដែលស្ដេចចុះទៅរាជតំណាក់ផែ។ ប្រធានរដ្ឋសភា ប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា , រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ចាងហ្វាងក្រុមព្រះរាជមន្ទីរ រង់ចាំក្រាបបង្គំទទួលព្រះករុណាជាអង្គម្ចាស់ ជីវិតលើត្បូង និងសម្ដេចព្រះមហាក្សត្រិយានី នៅមាត់ជណ្ដើរខាងលើ ហើយតាមហែ ព្រះអង្គទៅព្រះរាជតំណាក់ផែ ។

ម៉ោង ១៦.០០ សៀល ព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង និងសម្ដេចព្រះមហាក្សត្រិយានីស្ដេចយាងចេញពីព្រះបរមរាជវាំង ទៅគង់ប្រថាប់នៅក្នុងព្រះរាជ តំណាក់ផែ លុះត្រាតែរួចព្រះរាជពិធី ។

សូមជ្រាបថា ក្នុងព្រះរាជពិធីនេះ តាំងពីថ្ងៃដំបូងរហូតដល់ថ្ងៃបញ្ចប់ គ្រឿងទ្រង់ និងសំលៀកបំពាក់ ព្រះពស្ត្រពណ៌ ព្រះភូសាស័ក្តិ ព្រះអង្សា ឬស្ពាប់ព្រះជង្ឃ ព្រះភូសាសបើកព្រះសុរង ស័ក្តិព្រះអង្សា ។ សម្រាប់នាម៉ឺន សព្វមុខមន្ត្រី សំពត់ពណ៌ អាវកុតសស័ក្តិស្មា ឬខោជើងវែង អាវបើកក ស ។ សម្រាប់ទាហាន ខោវែងឯក សណ្ឋាន តាមក្រុម។ គ្រឿងឥស្សរិយស " ប៉ារេត" ។

នៅម៉ោង ១៩.០០ យប់មានអុចប្រទីបជ្វាលា នៅព្រះរាជតំណាក់ផែ និងទូកកប៉ាល់ ។ នៅពេលតំណាលគ្នានោះ ពិធីបណ្ដែតប្រទីប ដែលរចនារូបភាពផ្សេងៗ ក៏ចាប់ផ្ដើម ។ បណ្ដាប្រទីបទាំងនោះ ប្រទីបរបស់ព្រះមហាក្សត្រ មានត្រាមកុដជាសញ្ញា ។ ឯប្រទីបផ្សេងៗ ទៀត មាននិមិត្តសញ្ញារៀងៗ ខ្លួន ។

មុនពេលចេញដំណើរហែតាមដងទន្លេសាប ប្រទីបព្រះមហាក្សត្រ ដែលនៅមុខគេបំផុត អែបចូលទៅជិតព្រះរាជតំណាក់ផែ ហើយព្រះរាជាទ្រង់អុជប្រទីបនោះផ្ទាល់ព្រះអង្គដោយព្រះឈុតឈ្នួនដងវែង ដែលឧកញ៉ា ព្រះស្ដេចចាងហ្វាងសង្ឃការី ថ្វាយទ្រង់។

www.elibraryofcambodia.org

ប្រទីបដែលព្រះរាជាទ្រង់អុចនោះ ជាទៀនក្រមួនសុទ្ធ ខ្នាតតូចៗ ហៅទៀនភ៌រ ដែលបិទភាយភ្ជាប់ នៅរាងប្រទីចំនួន ៥០០ ដើម ។ ព្រះមហាក្សត្រទ្រង់អុជ៣ដើម សម្ដេចព្រះមហាក្សត្រិយានី អុជ ៣ដើម សម្ដេចព្រះឧបយុវរាជទ្រង់អុជ ៣ដើម ។ បន្ទាប់មក ព្រះរាជវង្សានុវង្ស នាម៉ឺនធំៗ ដែលគាល់ជិតព្រះករុណាអុជតៗទៅដរាបដល់គ្រប់ទៀនភ៌រ ៥០០ដើម ។

ក្រោយអុជទៀនហើយ កប៉ាល់សពោ្លងប្រទីបនោះចេញដំណើរបែរមុខទៅខាងជើង មាន ល្បឿនត្រឿនៗសន្សឹមៗច្រាសទឹកទៅតាមដងដៃទន្លេសាប ដល់មុខវត្តភ្នំដូនពេញ វិលត្រឡប់ចុះ បណ្ដោយទឹកមកវិញដល់មកមុខព្រះរាជ តំណាក់ផែ ត្រឡប់ឡើងច្រាសទឹកទៅលើវិញ សារចុះ សារឡើង ៣លើក ដរាបដល់ ម៉ោង ២២ យប់ ទើបឈប់ ។

ចាប់ពីម៉ោង ២៤ ដល់ភ្លឺ ពួកកញ្ញានារី ច្រៀងសករវ៉ាទ័ក្នុងព្រះរាជតំណាក់ផែ ដោយមានប្រគុំ ភ្លេងមហោរី ភ្លេងពិណពាទ្យ យ៉ាងពីរោះគ្រលួចគួចសោតិន្ទ្រិយារម្មណ៍ គួរឱ្យចង់សវនា ។

២. *ថ្ងៃទីពីរ គឺថ្ងៃ ១៥កើត ខែកត្ដិក ជាថ្ងៃកណ្ដាល សំពះព្រះខែ អកអំបុក*:

ចាប់ពីម៉ោង ១៦ .០០ តទៅ មានកម្មវិធីប្រណាំងទូក ង ទូកមូងដូចថ្ងៃទីមួយ ។

ចាប់ពីម៉ោង ២៤ .០០ យប់តទៅ មានព្រះរាជពិធីសំពះព្រះខែ អកអំបុកស្ថិតនៅទីខាងលើ មាត់ច្រាំងត្រង់ជណ្ដើរចុះទៅព្រះរាជតំណាក់ផែ នៅចំកណ្ដាលកម្រាល នោះ មានរៀបរណ្ដាប់ ផ្សេងៗ គឺអំបុក ២តោកធំ . ដូងខ្ចី ១០ផ្លែ .ចេកពងមាន់ ១០ស្និត . ទៀនតំណាងខេត្ត-ក្រុង ដោយមានជើងតំកល់សម្រាប់បង្ហិលសម្រក់ និងផ្លែឈើក្នុងស្រុកច្រើនមុខផ្សេងទៀត ។

ម៉ោង ២៤ .០០ ព្រះច័ន្ទពេញវង្ស ត្រង់ចំពីលើព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង សម្ដេច ព្រះមហាក្សត្រិយានី សម្ដេចព្រះ ឧបយុវរាជ ទ្រង់ស្ដេចចេញមកគង់ប្រថាប់កណ្ដាលទីប្រជុំ ដោយជួបជុំព្រះរាជវង្សានុវង្ស គណៈរដ្ឋមន្ត្រី និងនាម៉ឺនសព្វមុខមន្ត្រី គង់ អង្គុយត្រៀបត្រា ។

www.elibraryofcambodia.org

លុះជួបជុំហើយ ឧកញ៉ា ព្រះស្តេចចាងហ្វាង ក្រុមសង្ឃការី ក្រាបថ្វាយបង្គំចូលទៅអុជទៀនថ្វាយព្រះរតនត្រ័យ និងទេវតា នាំមនស្សិការព្រះរតនត្រ័យ និងសូត្រប្រកាសទេវតា ។

ប្រកាសទេវតាចប់ . ព្រះរាជាទ្រង់ស្តេចអុជទៀនទាំងគ្រប់តំណាងខេត្ត-ក្រុង រួចបង្វិលទៀនសម្រក់ផ្សែង សុំទឹកភ្លៀងឱ្យមកស្រោចស្រពក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យ កើតផលធ្វានុផលដ៏សម្បូណ៌សប្បាយដល់ប្រជារាស្ត្រ ។

លុះផ្សែងរួចហើយ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់ព្រះបរមរាជានុញ្ញាតព្រះរាជទានរណ្តាប់ដង្វាយទាំងឡាយមានអំបុកជាដើមដល់នាម៉ឺន សព្វមុខមន្ត្រី ទាំងឡាយឱ្យទទួលព្រះរាជទាន ជាទីកំសាន្តសប្បាយ ។

ចំនៀមអកអំបុក សំពះព្រះខែនេះ ប្រជាពលរដ្ឋ បានរៀបចំរណ្តាប់ដូចជា ព្រះរាជពិធីដែរ ។ នៅពេលអកអំបុក ប្រជារាស្ត្រ តែងងើយមុខឡើងមើលទៅដួងព្រះច័ន្ទដែលនៅកណ្តាលអម្ពរចំពីលើសិរសាប្រណមអញ្ជលី រួចហើយទើបលើកអំបុកឡើងអក ។ រីឯព្រះរាជពិធីក៏ធ្វើដូច្នោះដែរគ្រាន់តែមានរបៀបនឹងរណ្តាប់ឧត្តុង្គឧត្តមជាងពិធីរបស់រាស្ត្រប៉ុណ្ណោះ ។

៦. ** ថ្ងៃទីបី គឺថ្ងៃ ១រោច ខែកត្តិក ថ្ងៃបង្ហើយ ជាថ្ងៃកាត់ព្រ័ត្រ :*

ចាប់ពីម៉ោង ១៤.០០ រសៀល ពិធីប្រណាំង ទូក ង ទូកម៉ូង ក៏ចាប់ដំណើរការដោយមានតន្ត្រីព្រះរាជទ្រព្យ ភ្លេងពិណពាទ្យប្រគុំកំដរតាមសង្វាក់ទូកចុះឡើង ដូចថ្ងៃទី ១ និង ថ្ងៃទី ២ដែរ ។ ថ្ងៃទីបី គឺថ្ងៃ ១រោច ខែ កត្តិក ជាថ្ងៃបង្ហើយ មានការប្រណាំងទូកកាត់ព្រ័ត្រយ៉ាងឧឡារិកជាងថ្ងៃមុនៗ ។ ការផ្គូរទូកជាគូៗ ដូចថ្ងៃទី១ ទី២ ដែរ ប្លែកតែលើកទី៣ ចុងក្រោយបំផុតគឺការប្រមូលផ្តុំទូកទាំងអស់ទៅនៅដើមទី ទូកអុំ ដោយទូកអុំ ឯទូកចែវ ដោយទូកចែវហើយទូកទាំងនោះចេញស្របពេលស្មើគ្នាមកទាំងហ្វូងបែរមុខមកខាងត្បូងបណ្តោយទឹកមានអាការដូចជាខំនាំគ្នាបណ្តេញទឹកឱ្យស្រកហូរចុះទៅសមុទ្រឆាប់ៗប្រញាប់នឹងបង្កបង្កើនផល នារដូវ

www.elibraryofcambodia.org

ទឹកសម្រក ។

នៅទីផ្តាច់ព្រ័ត្រ មានបោះយុថ្កា ភ្ជាប់សំប៉ានមួយចំកណ្តាលទន្លេ ដៃទន្លេសាប ត្រង់មុខព្រះរាជដំណាក់ផែ មានភ្នាក់ងារម្នាក់ស្លៀកខោខៀវ ពាក់អាវក្រហម អង្គុយលើសំប៉ាននោះកាន់អន្ទុងចាំវាយស្គរតូចមួយ នៅពេលដែលទូកប្រណាំងមកដល់ទីនោះមួយលើក១ ជាសទ្ទសញ្ញាតាំងពីលើកទី១ ទី២ និងទី៣ ចុងក្រោយបំផុត ឱ្យដំណើងថា ទូកណាឈ្នះ ទូកណាចាញ់ ។ ធ្វើដូច្នេះតាំងពីថ្ងៃដំបូង ។ នៅថ្ងៃចុងក្រោយបំផុត គេសន្មត់ ហៅថា "**ព្រះរាជពិធីកាត់ព្រ័ត្រ** " ។

ពេលនោះ ពិធីកាត់ព្រ័ត្រ មានរូបភាពល្អមើលជាងពេលឯទៀត១ ដោយមានមហាជនរាប់ម៉ឺននាក់ រង់ចាំទស្សនា មាននេត្រាបាញ់ឆ្ពោះទៅរកទូកនៅកណ្តាលទន្លេ ដែលកំពុងបណ្តែតខ្លួនទៅទីកាត់ព្រ័ត្រនោះ ដោយសេចក្តីសប្បាយរីករាយយ៉ាងក្រៃលែង ។

ចាប់ពីម៉ោង ១៩ តទៅ មានព្រះរាជពិធីដូចថ្ងៃទី១ ។ ព្រះរាជពិធីបុណ្យអុំទូកត្រូវបានបញ្ចប់នៅថ្ងៃទី៣ ក្រោយបានប្រារព្ធពិធីប្រណាំងគ្រប់រយៈកាល ៣ថ្ងៃ ក្រោមបរិយាកាសរីករាយនិងអបអរសាទរ ។

www.elibraryofcambodia.org

***រំលឹកឆ្នាំ ១៩៧០_១៩៧៨ :**

ប៉ុន្តែ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុកនេះត្រូវបានអាក់ខាន ប្រារព្ធធ្វើអស់ជាច្រើនឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៧០ ក្នុងអំឡុងសង្គ្រាម ៥ឆ្នាំ នៃរបបសាធារណរដ្ឋខ្មែររបស់ លន់ ណុល និងត្រូវបានហាមឃាត់ដាច់ខាត ក្នុងចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៨ នៃរបបកម្ពុជាប្រជាធិបតេយ្យប្រល័យពូជសាសន៍ ប៉ុល ពត ។ រីឯព្រះរាជតំណាក់ផែ នៅមុខព្រះបរមរាជវាំង ក៏ត្រូវបានបំផ្លិចបំផ្លាញ គ្មានសល់ ។

***រំលឹកឆ្នាំ ១៩៧៩_២០០២ :**

ក្រោយថ្ងៃជ័យជំនះជាប្រវត្តិសាស្ត្រ ៧ មករា ឆ្នាំ ១៩៧៩ អតីតរដ្ឋកម្ពុជា បានបើកឱកាសជូនប្រជាពលរដ្ឋឱ្យរក្សានូវប្រពៃណី ទំនៀមទម្លាប់ នៃការប្រណាំងទូក ង កំសាន្ត សប្បាយនៅតាមវត្ត នៅតាមជនបទ ភូមិ ឃុំរបស់ខ្លួនឡើងវិញ ជារៀងរាល់ឆ្នាំ ។

ឆ្នាំមមី ទោស័ក ព.ស ២៥៣៤ ត្រូវនឹងថ្ងៃទី ០២ ខែវិច្ឆិកា ១៩៩០ ពិធីប្រណាំងទូក ង ទូកមួង ជាផ្លូវការលើទី ១ ត្រូវបានប្រព្រឹត្តទៅនៅតាមដងទន្លេសាប មុខព្រះរាជវាំង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេច ហេង សំរិន កាលនោះក្នុងឋានៈសម្តេចជា ប្រធានក្រុមប្រឹក្សានៃរដ្ឋកម្ពុជា ដោយមានទូក ង ទូកមួង ចូលរួម ប្រណាំងចំនួន ៤៣ ទូក មកពីខេត្ត-ក្រុង និងអង្គភាពមួយចំនួនគឺ ក្រុងភ្នំពេញ ៩ ទូក, ខេត្តកណ្តាល ១៥ ទូក, ខេត្តកំពង់ចាម ៦ ទូក, ខេត្តព្រៃវែង ៤ ទូក, ខេត្តកំពង់ឆ្នាំង ៤ ទូក, ខេត្តក្រចេះ ២ ទូក, និងស្នងការជើងទឹក ៣ ទូក ។

ចាប់ពីឆ្នាំ ១៩៩០ មក , ពិធីប្រណាំងទូក ង ទូកមួង ត្រូវបានប្រព្រឹត្តទៅជាប់ជានិច្ច រៀងរាល់ឆ្នាំ ដោយមានការចូលរួមពីថ្នាក់ដឹកនាំមន្ត្រីរាជការ អ្នកមុខអ្នកការ និងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ ពោរពេញដោយក្តីសប្បាយរីករាយ ។

www.elibraryofcambodia.org

រីឯចំនួនទូក ង និងទូកម្លង ក៏ចេះតែកើនចំនួនជាលំដាប់ និងត្រូវបានកែលំអចំនួនខ្ពង់ ចំណុះអ្នកអុំ កាន់តែលឿនលឿន កាន់ តែមានចំនួនច្រើនក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ខេត្ត-ក្រុង វត្តអារាមមួយចំនួន ដែលពុំ ធ្លាប់មានទូកង ទូកម្លង ក៏បានខិតខំកសាងទូក ង សម្រាប់ខេត្ត-ក្រុង និងសម្រាប់វត្តរបស់ខ្លួន ដើម្បីបានរួមចំណែកថែរក្សានូវប្រពៃណី ទំនៀមទម្លាប់ដ៏ល្អរបស់ជាតិ ។

ថ្ងៃ សុក្រ ១៥ រោច ខែផល្គុន ព.ស ២៣៣៥ ត្រូវនឹងថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៩៩១ វេទិកាកិត្តិយស អុំទូកមួយ ជាតំណាងព្រះរាជតំណាក់ផែ និងព្រះពន្លាតូចពីរ ក៏ត្រូវបានចាប់ផ្តើម សាងសង់ និងត្រូវបើកសម្ពោពអោយប្រើប្រាស់ជាផ្លូវការ នៅថ្ងៃ ពុធ ១៤ រោច ខែ កត្តិក ព.ស ២៥៣៥ ត្រូវនឹងថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ជាមួយគ្នានិងការរៀបចំពិធីប្រណាំងទូកង ជាផ្លូវការលើកទី ២ ។

គួរកត់សំគាល់ថា ចាប់តាំងពីមានការរៀបចំពិធីប្រណាំងទូកង ទូកម្លងឡើងវិញមក . ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាល តែងបានដាក់ចេញសារាចរណែនាំមួយ ស្តីពីការចាត់តាំងរៀបចំ ព្រះរាជពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក សំដៅធានាបានខ្លឹមសារ និងរូបភាពចាត់តាំង ស្របតាមប្រពៃណី ទំនៀមទម្លាប់របស់ជាតិផង និង បង្កើតការសប្បាយ រីករាយ ជូនប្រជាពលរដ្ឋផង ។

ផ្អែកលើខ្លឹមសារ សារាចរណែនាំ របស់រាជរដ្ឋាភិបាល. គណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ-អន្តរជាតិ តែងធ្វើផែនការណែនាំលំអិតមួយ ស្តីពីលក្ខណទាំងឡាយ នៃការជ្រើសរើសទូក ង ទូកចែវ ចូលរួមប្រណាំង ដោយតម្រូវឱ្យខេត្ត-ក្រុងនិមួយៗ ដែលមានទូកង ទូកចែវ ធ្វើការហ្វឹកហាត់សាកល្បងចំរាញ់ជ្រើសរើសទូកដែលមាន ល្បឿន លឿន និងមានលក្ខណៈសមស្រប ចូលរួមប្រណាំងនៅរាជធានីភ្នំពេញ ។

www.elibraryofcambodia.org

ដើម្បីធានាសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ និងបង្កការសប្បាយរីករាយក្នុងឱកាសបុណ្យអុំទូកម្តងៗគណៈកម្មការរៀបចំពិធីបុណ្យអុំទូក តែងដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងមួយសម្រាប់កីឡាករ កីឡាការិនីទូកប្រណាំងទូកទាំងអស់អនុវត្ត ។

**ខ្លឹមសារនៃបទបញ្ជាផ្ទៃក្នុងមានកំណត់ :**

- អំពីទំនៀមទម្លាប់ និងប្រពៃណីជាតិ
- អំពីការប្រលងប្រណាំងផ្នែកសោភ័ណ្ឌភាព ប្រពៃណី វប្បធម៌
- អំពីសន្តិសុខ សណ្តាប់ធ្នាប់ និងវិន័យ
- អំពីបទបញ្ជាបច្ចេកទេសក្នុងការរៀបប្រណាំង
- អំពីរបៀបរបបប្រមូលផ្តុំ ការចាប់គូ និងទីតាំងប្រណាំង
- អំពីកំហុសក្នុងពេលប្រណាំង
- អំពីពិធីចាប់កូនខ្លែង កាត់ព្រ័ត្រ ។

ដោយពីមួយឆ្នាំទៅមួយឆ្នាំ ទូកង ទូកចែវ កាន់តែមានចំនួនច្រើន ឯពេលវេលាមានកំណត់ត្រឹមតែបីថ្ងៃ ម្ល៉ោះហើយ ការប្រណាំងទូកងពុំអាចនឹងចាត់តាំងប្រណាំងពីរជើង ឬបីជើង ដូចក្នុងសម័យទសវត្សឆ្នាំ ៥០ ឬ ៦០ បានឡើយ ។ គឺយើងរៀបចំការប្រណាំងបានតែមួយជើងប៉ុណ្ណោះ ក្នុងមួយថ្ងៃ និងធ្វើការចាប់ឆ្នោតខ្សែទឹកក្នុងខ្សែទឹកក្រៅ ។

យើងបានរៀបចំទីលានប្រណាំងទូកមានចំងាយ ១.៧០០ ម បែងចែកជាចំណុចចាប់ផ្តើមត្រង់ផែថ្ម បន្ទាប់មក កងពន្ធ័ទី១ . កងពន្ធ័ទី២ និងទីផ្តាច់ព្រ័ត្រ។ ពីចំណុចចាប់ផ្តើមមកកងពន្ធ័ទី ១ ចំងាយ ១.០០០ ម ពីកងពន្ធ័ទី១ មកកងពន្ធ័ទី២ ចំងាយ ៥០០ ម ។
ពីកងពន្ធ័ទី២ មកផ្តាច់ព្រ័ត្រ ចំងាយ ២០០ ម ។ នៅចុងទីផ្តាច់ព្រ័ត្រមានទូកស្តរជ័យពីរមួយនៅខាងខ្សែទឹកក្នុង និងមួយទៀតនៅខ្សែទឹកក្រៅ សម្រាប់ទូងស្គរ ជាសញ្ញាប្រាប់ថាទូកណា

www.elibraryofcambodia.org

ដល់ទីផ្តាច់ព្រ័ត្រមុន ក្រោយ ។ នៅចំពីមុខទីផ្តាច់ព្រ័ត្រ មានគុគណៈកម្មការមេប្រយោគដែលមានសមាជិកជាច្រើននាក់សម្រាប់ស្រង់ពិន្ទុនៃគូទូកនិមួយៗ ។ គណៈមេប្រយោគមានទូរទស្សន៍សម្រាប់ថតយកទិដ្ឋភាពទូទៅនៃការប្រណាំងទូកពិសេស គឺថតយកត្រង់ទីផ្តាច់ព្រ័ត្រ សម្រាប់ធ្វើការបូកសរុប វាយតម្លៃផ្តល់ពិន្ទុនៃទូកដែលមានល្បឿនប្រហាក់ប្រហែលគ្នា ជៀសវាងការតវ៉ាយកឈ្នះរៀងខ្លួនរបស់កីឡាករ កីឡាការិនី ម្ចាស់ទូកនិមួយៗ ។

**លទ្ធផលឈ្នះនិងចាញ់ ត្រូវបា[illegible]ជា ៤ ប្រភេទគឺ :**

១ - ការឈ្នះដោយសង្កត់ក្បាល

២ - ការឈ្នះពាក់កណ្តាលទូក "សង្កត់ពាក់កណ្តាលទូក"

៣ - ការឈ្នះគាស់ទំពក់ "សង្កត់របៀបគាស់ទំពក់ "

៤ - ការឈ្នះដោយដាច់ផុតពីគ្នាតែម្តង "ឈ្នះដាច់"

ការចំណាត់ថ្នាក់ ត្រូវបានកំណត់ចែកចេញជា៤ ផែន គឺ : ផែនលេខ១ .ផែនលេខ២ ផែនលេខ៣ និង ផែនលេខ៤ ។

ទូកទាំងឡាយ ដែលបានប្រកួតបានឈ្នះគូរបស់ខ្លួន នៅក្នុងការប្រកួត នាថ្ងៃទីមួយ និងថ្ងៃទីពីរ " គូរដែលគ្រាន់តែដូរខ្សែទឹក " នឹងត្រូវឡើងទៅប្រកួតផ្តាច់ព្រ័តយកចំណាត់ថ្នាក់លេខ ១ និងលេខ ២ នៅថ្ងៃទីបី ជាមួយទូកដែលបានឈ្នះដូចគ្នា ។ ទូកទាំងឡាយ ដែលបានប្រកួតចាញ់ដៃគូរបស់ខ្លួន ក្នុងការប្រកួតជាថ្ងៃទីមួយ និងថ្ងៃទីពីរ នឹងត្រូវឡើងទៅប្រកួតនៅថ្ងៃទីបីទៀតដែរ ក្នុងចំណោមទូកដែលចាញ់ដូចគ្នា និង ដណ្តើមយកចំណាត់ថ្នាក់លេខ៣ និងលេខ ៤។ ទូកដែលចាញ់ក្នុងការប្រកួតនៅថ្ងៃទីបីនេះ នឹងចាត់ក្នុងចំណាត់ថ្នាក់លេខ៤ ។

ទន្ទឹមនឹងការផ្តល់ពិន្ទុផ្នែកល្បឿន គណៈកម្មការ មេប្រយោគក៏បានធ្វើការផ្តល់ ពិន្ទុទៅលើផ្នែកសោភ័ណភាព ប្រពៃណី និងវប្បធម៌ ដោយកំណត់ទៅលើលក្ខណៈសម្បត្តិចំនួន ៥ ចំណុច :

www.elibraryofcambodia.org

ពិន្ទុទៅលើផ្នែកសោភ័ណភាព ប្រពៃណី និងវប្បធម៌ដោយកំណត់ទៅលើលក្ខណៈសម្បត្តិចំនួន ៥ ចំណុច :

១ - សោភ័ណភាពនៃការតុបតែង រំលេចក្បាច់រចនារបស់ទូកនិមួយៗ

២ - សំលៀកបំពាក់ជាឯកសណ្ឋានប្រពៃណីជាតិរបស់កីឡាករអុំទូក

៣ - សំលៀកបំពាក់ និងកាយវិការរបស់អ្នកបញ្ជាទូក

៤ - ការគ្រប់គ្រង និងសាមគ្គីភាពផ្ទៃក្នុងក្រុម និងជាមួយកីឡាករផងគ្នា

៥ - ការគោរពបទបញ្ជា និងគោលការណ៍កំណត់ទាំងឡាយរបស់គណៈកម្មការ ។

ទូកទាំងឡាយណា ដែលមានលក្ខណសម្បត្តិទាំង៥ ចំណុចក្នុងកម្រិតខ្ពស់ជាងគេ ត្រូវគណៈកម្មការមេប្រយោគចាត់ចំណាត់ថ្នាក់ តាមលំដាប់លេខ១ ដល់លេខ៣ ទាំងទូកអុំទាំងទូកចែវទាំងបុរសនិងទាំងនារី ។ យើងមានផែនការណែនាំ និងមានបទបញ្ជាច្បាស់លាស់សម្រាប់ឱ្យក្តីឡាតរកីឡាការនីទូកនិមួយៗអនុវត្ត សំដៅធានារក្សាបានប្រពៃណី ទំនៀមទំលាប់ដ៏ល្អរបស់ជាតិផង និងសាមគ្គីភាព វិន័យ សេចក្តីថ្លៃថ្នូរ កិត្តិយសផង ព្រមទាំងបង្កលក្ខណៈសច្ចាវីរៈភាពជាទូទៅផង ។ ទូកអុំ ទូកចែវទាំងអស់ ត្រូវបានទទួលការឧបត្ថមជាសម្ភារៈ ពិសេស ទង់ផ្កាកិត្តិយស នូវប្រាក់សង្កត់ក្បាលទូក និងរបបហូបចុកគ្រប់រយៈពេល ៣ ថ្ងៃដូចគ្នា ។ ក្រោយបញ្ចប់ការប្រណាំង ទូកទាំងអស់នឹងត្រូវបានទទួលរង្វាន់ជ័យលាភី តាមកម្រិត ចំណាត់ថ្នាក់នៃទូកនីមួយៗតាមការកំណត់របស់គណៈកម្មការ ។ យើងសូមស្រង់ចំនួនទូក ១ ទូកម្តង តាមលំដាប់ឆ្នាំចាប់ពីឆ្នាំ១៩៩០ រហូតមកដល់ឆ្នាំ ២០០២ ដូចខាងក្រោមនេះ :

*ចំនួន "ទូកអុំ-ទូកចែវ " ដែលបានចូលរួមប្រណាំងក្នុង ១ឆ្នាំៗ ចាប់ពីឆ្នាំ ១៩៩០ មកដល់ឆ្នាំ ២០០១-២០០២*

www.elibraryofcambodia.org

*ថ្ងៃទី ០២-០៣ ខែវិច្ឆិកា ឆ្នាំ ១៩៩០ :

ទូកសារុប : ៤៣ ទូកមាន ទូកអុំ និង ទូកចែវ បុរស-នារី

*ថ្ងៃទី ២០-២១-២២ ខែវិច្ឆិកា ឆ្នាំ ១៩៩១ :

ទូកសារុប : ១០០ . អុំបុរស ៦២ . ចែវបុរស ៣១ . ចែវនារី ៧ . កម្លាំងសរុប ៤.៤៦៤ នាក់.

*ថ្ងៃទី ៨-៩-១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩២ :

ទូកសារុប : ១៤០ . អុំបុរស ៩៥ . អុំនារី ០៤ ចែវបុរស ៣១ . ចែវនារី ១០ .

កម្លាំងសរុប ៧.៨៧៨នាក់។

*ថ្ងៃទី ២៧-២៨-២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

ទូកសរុប : ១៩៨ . អុំបុរស ១៤៧ . អុំនារី ៦ . ចែវបុរស ៣៦ . ចែវនារី ៩ .

កម្លាំងសរុប ៩.៨៩៣នាក់ ។

*ថ្ងៃទី ១៧-១៨-១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ :

ទូកសរុប : ២០៤ . អុំបុរស ១៥៥ . អុំនារី ៤ . ចែវបុរស ៣៤ . ចែវនារី១១ .

កម្លាំងសរុប ១០.៥៥០ នាក់ ។

*ថ្ងៃទី ០៦-០៧-០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ :

ទូកសរុប : ២៥១ . អុំបុរស ១៩៨ . អុំនារី ៤ . ចែវបុរស៣ ៧៨ . ចែវនារី ១១

កម្លាំងសរុប ១៣.១០២នាក់ ។

*ថ្ងៃទី ២៤-២៥-២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ :

ទូកសរុប : ៣១០ . អុំបុរស ២៥១ . អុំនារី ៦ . ចែវបុរស ៤២ . ចែវនារី ១១

កម្លាំងសរុប ១៦.៦៥៥ នាក់ ។

www.elibraryofcambodia.org

*ថ្ងៃទី ១៣-១៤-១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ :

ទូកសរុប : ៣១៤ , អុំបុរស ២៦១ . អុំនារី ៥ . ចែវបុរស ៣៩ . ចែវនារី ៩ .

កម្លាំងសរុប ១៧,៦៧៧ ។

*ថ្ងៃទី ០២-០៣ -០៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ :

ទូកសរុប : ៣០៣ . អុំបុរស ២៩៥ . អុំនារី ២ . ចែវនារី ៦ .

កម្លាំងសរុប ១៨.០៥៥ នាក់ ។

*ថ្ងៃទី ២១-២២ -២៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ :

ទូកសរុប : ៣៧៧ . អុំបុរស ៣១៨ . អុំនារី ១០ . ចែវបុរស ៤៣ . ចែវនារី ៦.

កម្លាំងសរុប ២១ . ៨៩០ នាក់ ។

*ថ្ងៃទី ១០-១១ -១២ ខែវិច្ឆិកា ឆ្នាំ ២០០០ :

ទូកសុរប : ៣៨៤ . អុំបុរស ៣២៦ . អុំនារី ៥ . ចែវបុរស ៤៩ . ចែវនារី ៤ .

កម្លាំងសរុប ២៤.០៧៥ នាក់ ។

*ថ្ងៃទី ៣០-៣១ ខែតុលានិងថ្ងៃទី០១ ខែវិច្ឆកា ឆ្នាំ ២០០១ :

ទូកសុរប : ៤០១ . អុំបុរស ៣៣៨ . អុំនារី ៧ . ចែវបុរស ៥១ . ចែវនារី ៥ .

កម្លាំងសរុប ២៤.៧៥១ នាក់ ។

*ថ្ងៃទី ១៨-១៩ និង២០ ខែវិច្ឆិកា ឆ្នាំ ២០០២ :

ទូកសុរប : 406 អុំបុរស31 អុំនារី6 ចែវបុរស54 ចែវនារី6

កម្លាំងសរុប 25 851 នាក់.

ភ្នំពេញ , ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០២

អគ្គលេខាធិការដ្ឋាននៃគណៈកម្មការអចិន្ត្រៃយ៍

រៀបចំបុណ្យជាតិ -អន្តរជាតិ

www.elibraryofcambodia.org

# ទូក ១ " ទូកអុំ - ទូកចែវ "

# ដែលបានចូលរួមប្រណាំងក្នុងឱកាសបុណ្យអុំទូកឆ្នាំ ២០០១-២០០២

| ឈ្មោះទូក | វត្ត | ឃុំ-សង្កាត់ | ស្រុក-ខ័ណ្ឌ | ចំពោះទូក | ផ្សេងៗ |
|---|---|---|---|---|---|

## រាជធានីភ្នំពេញ

| | | | | | |
|---|---|---|---|---|---|
| មហាសែនតេជះ | មហាមន្ត្រី | អូឡាំពិក | ចំការមន | ៥៣ | អុំប្រុស |
| មហានាគ | នាគវ័ន | បឹងកក់ ២ | ទួលគោក | ៥៩ | - |
| នាគរាជ | ពូនភ្នំ | សំរោងក្រោម | [illegible] | ៥៧ | - |
| កន្ទោងខៀវមានរិទ្ធិ | ជើងឯក | ដង្កោ | ដង្កោ | ៤៧ | - |
| មហាគ្រុឌ | ចាក់ខែង | ព្រែកលៀប | ឫស្សីកែវ | ៦០ | - |
| ឃ្មួញវរៈសែនជ័យ | ឃ្មួញ | ឃ្មួញ | ឫស្សីកែវ | ៤៩ | - |
| ពិសីសិរីសាគរ | ប្រជុំសាគរ | ជ្រោយចង្វា | ឫស្សីកែវ | ៤៩ | - |
| សំរែករាជសីហ៍ | ញាណរង្សី | ទួលសង្កែ | ឫស្សីកែវ | ៦០ | - |
| ពោធិមានជ័យ | ពោធិព្រឹក្ស | ព្រែកលៀប | ឫស្សីកែវ | ៤៩ | - |
| មហិទ្ធិឫទ្ធិរាជសីហ៍ | នាគវ័ន រការខ្នុរក្រោម | | ក្រុងភ្នំពេញ | ៥៤ | - |
| មហារាជសីហ៍បារមីមានឫទ្ធិ | ហ្លួងរការខ្នុរ កណ្តាល | | ក្រុងភ្នំពេញ | ៥៤ | - |
| ដូនពេញសែនជ័យ | បទុមវតី | ចតុមុខ | ដូនពេញ | ៥៧ | - |
| ៧មករា | មង្គលវ៉ង | [illegible] | ៧មករា | ៥៨ | - |

www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| នាគខៀវមានជ័យ | ចាក់អង្រែក្រោម | ចាក់អង្រែ | មានជ័យ | ៦១ | អុំបុរស |
| នាគខ្មៅមានជ័យ | ចាក់អង្រែក្រោម | ចាក់អង្រែ | មានជ័យ | ៥១ | - |
| បក្សីចាំក្រុង | វិហារឯករង្សី | ជ្រោយចង្វា | ឫស្សីកែវ | ៣៦ | ចែវបុរស |
| តារាសែនជ័យរស្មីមេគង្គ | វិហារគូឡាឡោម | ជ្រោយចង្វា | ឫស្សីកែវ | ៣៦ | - |

## ខេត្ត កំពង់ឆ្នាំង

| | | | | | |
|---|---|---|---|---|---|
| ព្រះពៃស្រពណ៍ | ព្រះពៃស្រព | ជលសា | ជលគីរី | ២៦ | ចែវនារី |
| ហនុមាន មានឫទ្ធិ | ពាមឆ្កោក | ពាមឆ្កោក | ជលគីរី | ៣០ | ចែវបុរស |
| រស្មីសិរីសោភា | កោះថ្កូវ | កោះថ្កូវ | ជលគីរី | ៣២ | - |
| រស្មីសិរីសោភ័ណ | កោះថ្កូវ | កោះថ្កូវ | ជលគីរី | ៣០ | - |
| សន្ទះរាជសីហ៍គិរីទសែនជ័យ បារមីមានរិទ្ធិ | | កោះថ្កូវ | ជលគីរី | ៣៨ | - |
| គីរីទួសែនជ័យរស្មីគរជ្រុំ | | កោះថ្កូវ | ជលគីរី | ៣៥ | - |
| រន្ទះពេជ្រសែនជ័យ | | | កំពង់ត្រឡាច | ៦៦ | អុំបុរស |
| ព្រះរាមថ្លែងសរ | ព្រះពៃស្រពណ៍ | ជលសា | ជលគីរី | ៣៩ | ចែវបុរស |
| សារាយអណ្តែត | វត្តថ្មី | តាជេស | កំពង់ត្រឡាច | ៣០ | - |
| ម៉ឺននាគ | កំពង់ព្រះ | ភ្នុកទ្រ | បរិបូណ៌ | ៣១ | - |
| ពុទ្ធិសែនមានជ័យ បារមីពោធិអណ្តែត | ពោធិសត្ថារាម | កំពង់លែង | កំពង់លែង | ៣៥ | - |

## ខេត្ត កំពង់ចាម

| | | | | | |
|---|---|---|---|---|---|
| ចៅពេជ្រកុមារបុប្ផាជ្រោយថ្ម | សុទស្សនារាម | បឹងកុក | កំពង់ចាម | ៥៧ | អុំបុរស |

www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| សុវណ្ណកុមារមហាបុរី រតនៈមានជ័យ | បទុមរតនៈ ជីដុះ | វាលវង់ | កំពង់ចាម | ៦៥ | អុំបុរស |
| ច័ន្ទសុវណ្ណសែនជ័យ | ជោតនារាម | បឹងកុក | កំពង់ចាម | ៦០ | - |
| ព្រះភិរុណសែនជ័យ | មុនិរង្សី | មៀន | អូរាំងឪ | ៦០ | - |
| ព្រះនាគសែនភិរុណមានជ័យ | ព្រះធាតុបាស្រី | ព្រះធាតុថ្មដា | អូរាំងឪ | ៦០ | - |
| អធិរាជបឹងធំ | បឹងធំ | មៀន | ព្រៃឈរ | ៦១ | - |
| ព្រះខ័នរិទ្ធ | ឧទុម្ពរ | ព្រះអណ្តូង | ស្ទឹងត្រង់ | ៤៧ | - |
| បទុមបុប្ផ | បទុមកេសរ | ពាមកោះស្នា | ស្ទឹងត្រង់ | ៥២ | - |
| នារីផ្កាយព្រឹក | ភ្នំជ័យគិរី | ព្រែកបាក់ | ស្ទឹងត្រង់ | ៥៣ | - |
| ជប់ច័ន្ទសែនជ័យ | ឧទុម្ពរវនារាម | ជីរោទិ៍ ១ | ត្បូងឃ្មុំ | ៥៧ | - |
| ព្រឹក្សាសែនជ័យរស្មីពាមជីលាំង | មង្គលរង្សី | ពាមជីលាំង | ត្បូងឃ្មុំ | ៥៧ | - |
| សិរីមានជ័យបារមីពាមចក | ជោតនារាម | ទន្លេបិទ | ត្បូងឃ្មុំ | ៦១ | - |
| ជប់ច័ន្ទព្រះខ័នរាជសែនជ័យ | គិរីវនារាម | វិហារលួង | ត្បូងឃ្មុំ | ២២ | អន្តរជាតិ |
| ពោធិព្រឹក្សមានជ័យ | ពោធិព្រឹក | ក្រូចឆ្មារ | ក្រូចឆ្មារ | ៤៦ | អុំបុរស |
| បទុមរិទ្ធ | បទុមវតី | ស្វាយឃ្លាំង | ក្រូចឆ្មារ | ៤៣ | – |
| សិរីឫទ្ធី | និគ្រោធារាម | ប៉ើស ២ | ក្រូចឆ្មារ | ៤៥ | - |
| ព្រះទិនាំងមនោមៃយ្យ | មហានិទ្ធិរោរាម | ខ្សាច់ក្រោម | ក្រូចឆ្មារ | ៤៨ | - |
| ព្រះខ័នរាជ្យ | កោះព្រែង | កោះពីរ | ក្រូចឆ្មារ | ៥៧ | - |
| សុវណ្ណគង្គា | វាលុការាម | ក្រូចឆ្មារ | ក្រូចឆ្មារ | ៤៥ | - |
| នាងរំដាយដាត់ | មហាលាភ | មហាលាភ | កោះសូទិន | ៤៦ | - |
| ព្រះខ័នពេជ្រមានរិទ្ធ | ដំណាក់ព្រីង | មហាលាភ | កោះសូទិន | ៦២ | - |

www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| ព្រះច័ន្ទសែនជ័យ | ឧបោសថវ៉ែន | ល្វេ | កោះសូទិន | ៥១ | អុំបុរស |
| បុប្ផាកន្លង់ពេជ្រ | ទន្សាយគោង | ល្វេ | កោះសូទិន | ៤១ | អុំនារី |
| មហាតេជះព្រះវិស្ណុ | ទន្សាយគោង | ល្វេ | កោះសូទិន | ៦៤ | អុំបុរស |
| មហាព្រហ្មមានរិទ្ធិ | សុទ្ធាវត្សារាម | កោះសូទិន | កោះសូទិន | ៥៩ | - |
| ចំប៉ាពេជ្រ | ទីប្រជុំមុងកោះ | កោះសូទិន | កោះសូទិន | ៦០ | - |
| រិទ្ធីនាគរាជ | មហាមង្គល | មហាខ្នង | កោះសូទិន | ៤៥ | - |
| រតនរង្សីបារមីគីរីឫទ្ធិ | រតនរង្សី | ល្វេ | កោះសូទិន | ៦០ | - |
| រតនរង្សីជ័យចំរើន | រតនរង្សី | ល្វេ | កោះសូទិន | ៤៥ | - |
| តាទិលសែនជ័យ | វិបស្សនារាម | ល្វេ | កោះសូទិន | ៦០ | - |
| ហនុមាន | សំពងព្រះជីរ៍ | ព្រែកតានង | កោះសូទិន | ៥៥ | - |
| មហិទ្ធិរិទ្ធិមហាគ្រុឌ | ពាមក្នុង | ព្រែកក្របៅ | កងមាស | ៥៧ | - |
| មហិទ្ធិរិទ្ធិមហាជម្ពូ | និគ្រោធារាម | ពាមជីកង | កងមាស | ៥៤ | - |
| មហាទន្សាយសែនជ័យ | គជវនារាម | រ៉ាយប៉ាយ | កងមាស | ៥៥ | - |
| កងពេជ្រមានជ័យ<br>រស្មីឧត្តម | កងតាណឹង | កងតាណឹង | កងមាស | ៦៤ | - |
| ផ្គរលាន់ | មុនីសាគរ | ខ្ចៅ | កងមាស | ៦៥ | - |
| កងមាសមានជ័យ | ពាមជីកង | ពាមជីកង | កងមាស | ៥៧ | - |
| រស្មីពេជ្រគីរី | ស្វាយពាន់ | ខ្ចៅ | កងមាស | ៥៨ | - |
| ច័ន្ទរង្ស៊ះពេជ្រ | វិរិន្ទមង្គល | ខ្ចៅ | កងមាស | ៦០ | - |
| មហិទ្ធិរិទ្ធិមហាស្វាំង | មុនីកែវសួរក្យាគន្ធ | សូគង | កងមាស | ៥៤ | - |
| ឆក់វិយសែនជ័យ | មទុមមុនីវ៉ន | ស្ដៅ | កងមាស | ៥៧ | - |
| គង្គារស្មីស្ដិបទុម | ស្ដិបទុម | ព្រែកកុយ | កងមាស | ៥០ | - |
